YUNNAN DAILY PRESS GROUP

# សម្រស់ យូណាន

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 23 លេខ 6697 ថ្ងៃ សុក្រ ទី10 ខែ មេសា ឆ្នាំ 2015

## ឱកាសធ្វើពាណិជ្ជកម្ម ក្នុងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ អាស៊ីខាងត្បូង

"ជម្រាបសួរលោក ខ្ញុំចង់ជួលកន្លែងពិព័រណ៍មួយនៅក្នុងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិអាស៊ីខាងត្បូងសម័យនេះសម្រាប់តាំងពិព័រណ៍សិប្បកម្ម និងផលិតផលធ្វើពីឈើ សូមសួរកន្លែងពិព័រណ៍មួយដែលមានទំហំ៩ ម៉ែត្រក្រឡា គឺថ្លៃប៉ុន្មាន?"។ នៅដើមខែមីនានេះ លោក ZeshanShaukat បានសួរអំពីព័ត៌មានពីពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិអាស៊ីខាងត្បូងសម័យនេះតាមគេហទំព័រជាភាសាអង់គ្លេសនៃកាសែតយូនណានដេលី (english.yunnan.cn)។

"ពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិអាស៊ីខាងត្បូងមានឱកាសធ្វើពាណិជ្ជកម្ម" ត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើងដោយមិត្តភក្តិក្នុងស្រុក និងបរទេស ។ ពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិអាស៊ីខាងត្បូងសម័យនៅឆ្នាំមុន ភ្ញៀវដែលមកពីគ្រប់ប្រទេសបានប្រមូលផ្តុំគ្នានៅគុនមីង បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអំពីគម្រោងវិនិយោគសរុបមាន ៥០៨គម្រោង មានប្រមាណសរុបប្រហែល៧០៨,២ពាន់លានយាន់ បានកើនឡើង១៨ភាគរយ ប្រហែលជា ១.១០០ ពាន់លានយាន់ បើប្រៀបធៀបនឹងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិអាស៊ីខាងត្បូងសម័យដំបូងៗក្នុងចំណោមគម្រោងទាំងនេះកិច្ចព្រមព្រៀងសហការក្នុងស្រុកចំនួន៤៥២ត្រូវជា៦៥២,៦ពាន់លានយាន់ជាសរុប ហើយគម្រោងវិនិយោគពីបរទេសមានចំនួន៥៦ ត្រូវជា៩,០៨ពាន់លានដុល្លារ។

ឱកាសធ្វើពាណិជ្ជកម្មមិនគ្រាន់តែស្ថិតក្នុងកិច្ចព្រមព្រៀងទេ ថែមទាំងកប់ក្នុងកន្លែងពិព័រណ៍ដែរ ។ ឆ្នាំទៅ ប្រទេសនេប៉ាល់ គឺជាប្រទេសជាប្រធានបទ ហើយនៅមានរោងពិព័រណ៍ដោយឡែកមួយសម្រាប់ប្រទេសជាប្រធានបទ ។ គ្រួសាររបស់លោកអ៊ូ យូ និងលោកស្រី យាន យីន ដែលជាគ្រួសារចិន-នេប៉ាល់មួយ គេបានមកចូលរួមពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិអាស៊ីខាងត្បូងនៅឆ្នាំមុន ដើម្បីអាជីវកម្មទេសចរណ៍របស់គេ ។ តាមរយៈការផ្សព្វផ្សាយនៅលើពិព័រណ៍អន្តរជាតិលើកនេះ លោកអ៊ូ យូ កាន់តែល្បីនាមក្នុងវិស័យទេសចរណ៍ ឥឡូវនេះអាជីវកម្មរបស់លោកបានកាន់តែរីកចម្រើនហើយ ។

តាមព័ត៌មានថា ក្នុងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិអាស៊ីខាងត្បូងឆ្នាំនេះ ខេត្តយូនណាន នឹងអាស្រ័យលើគុណសម្បត្តិរបស់ខ្លួនប្រមូលសហគ្រាសល្បីល្បាញ និងសហគ្រាសមានកម្រិតបច្ចេកវិជ្ជាខ្ពស់កាន់តែច្រើនមកចូលរួម ហើយនឹងខំប្រឹងសូមអញ្ជើញពាណិជ្ជករល្បីឈ្មោះ ឥស្សរជន និងមន្ត្រីកាន់តែច្រើន ។

ថ្ងៃទី២ ខែមីនានេះ ក្រសួងពាណិជ្ជកម្មប្រទេសចិន និងរដ្ឋាភិបាលខេត្តយូនណាន បានប្រារព្ធធ្វើសន្និសីទផ្សព្វផ្សាយនៃពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងសម័យទី៣- ពិព័រណ៍ពាណិជ្ជកម្មគុនមីញ សម័យទី២៣ នៅក្នុងទីក្រុងប៉េកាំង ។ មានមន្ត្រីការទូតជាង ៦០នាក់ ដែលមកពី៣១ ប្រទេសនៃអាស៊ីអាគ្នេយ៍អាស៊ីខាងត្បូង អឺរ៉ុប និងអាហ្វ្រិក និងអ្នកតំណាង ២១ នាក់ នៃសហគ្រាសនានាបានចូលរួម ។ ពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងលើកនេះនឹងធ្វើឡើងនៅមជ្ឈមណ្ឌលតាំងពិព័រណ៍អន្តរជាតិទានជី នៃទីក្រុងគុនមីញ មជ្ឈមណ្ឌលតាំងពិព័រណ៍នេះ អាចផ្តល់កន្លែងពិព័រណ៍ស្តង់ដារប្រហែល ៦.០០០ មានទ្រង់ទ្រាយធំជាងមុនមួយជាពីរបើប្រៀបនឹងពិព័រណ៍ឆ្នាំមុន នឹងផ្តល់សេវាកម្មកាន់តែប្រសើរចំពោះសហគ្រាសនិងពាណិជ្ជករនានា។

មិនត្រឹមតែប៉ុណ្ណោះទេ ខេត្តយូនណាន បានទទួលឱកាសកាន់តែល្អជាងនៅឆ្នាំនេះ គឺកសាង"មជ្ឈមណ្ឌលវិទ្យុសកម្មអាស៊ីខាងត្បូងអាស៊ីអាគ្នេយ៍" ដែលនិងជំរុញការរីកចម្រើននៃខេត្តយូណាន កាន់តែឆាប់ឡើង ។ ឆ្លៀតឱកាសល្អនេះ ខេត្តយូនណាននឹងអភិវឌ្ឍន៍ជាអាទិភាពនូវឧស្សាហកម្មកំពុងរីកចម្រើនទាំងប្រាំមួយគឺ ជីវវេជ្ជសាស្ត្រ និងជីវឱសថសាស្ត្រ ការកែច្នៃម្ហូបអាហារកសិកម្ម ពិសេសលោហធាតុមិនមានជាតិដែក និងកម្រមាន និងសម្ភារៈថ្មី រថយន្ត និងគ្រឿងយន្តល្បឿនលឿន ប្រេងកាត និងគីមីវិទ្យា និងព័ត៌មានអេឡិចត្រូនិក ។ សូមអញ្ជើញមកទស្សនាពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិអាស៊ីខាងត្បូងលើកទី៣ ដើម្បីស្វែងរកឱកាសពាណិជ្ជកម្មចុះ៕ **ឈូ ដុងហ្វា**

## កីឡាករបរទេសចាប់ចិត្តនឹងការហ្វឹកហ្វឺននៅខ្ពង់រាបខេត្តយូនណាន



បច្ចុប្បន្ននេះ មូលដ្ឋានហ្វឹកហ្វឺនជលកីឡា ដែលស្ថិតនៅឃុំសុងម៉ាវ ស្រុកឆឹងកុង ទីក្រុងគុនមីញ បានទទួលកីឡាករក្រុមជាតិភូមាពួកគេនឹងហ្វឹកហ្វឺនអស់រយៈពេល២ខែនៅទីក្រុងគុនមីញ។

ដើម្បីចូលរួមសន្និសីទកីឡាអាស៊ីអាគ្នេយ៍សម័យទី២៨ ដែលនឹងធ្វើឡើងនៅប្រទេសសិង្ហបុរីនៅពេលខាងមុខនេះ ប្រទេសភូមាបានចូលរួមកម្មវិធីហ្វឹកហ្វឺនមួយដែលផ្តល់ដោយប្រទេសចិន។ កីឡាករប្រទេសភូមាចំនួនជាង ៤០០ នាក់ ដែលមកពីក្រុមកីឡាភូមាចំនួនជាង ១០ នឹងមកហ្វឹកហ្វឺននៅប្រទេសចិន។ លោក THETLWINOO អ្នកទទួលខុសត្រូវនៃគណៈប្រតិភូកីឡាភូមា បានសម្តែងអំណរគុណដល់ការគាំទ្រពីប្រទេសចិនថា នៅក្នុងសន្និសីទកីឡាអាស៊ីអាគ្នេយ៍សម័យទី ២៧ គណៈប្រតិភូកីឡាភូមាបានទទួលលទ្ធផលល្អ ដែលបានទទួលចំនួនមេដាយមាសច្រើនទី២ លទ្ធផលដ៏ល្អនេះ មិនអាចឃ្លាតពីការជំនួយពីប្រទេសចិនដែរ លើកនេះគណៈប្រតិភូកីឡាភូមានឹងខំប្រឹងព្យាយាមដើម្បីផលល្អទៀត។

ទីក្រុងគុនមីញស្ថិតនៅខ្ពង់រាបដែលមានកម្ពស់ប្រហែល ១៩០០ ម៉ែត្រ មានធាតុអាកាសស្រួលណាស់ មានមូលដ្ឋានហ្វឹកហ្វឺនថ្នាក់កំពូលជាច្រើនសម្រាប់កីឡាច្រើនប្រភេទ ដូចជា track and field ការជិះកង់ ការហែលទឹក និងកីឡាបាល់ទាត់ជាដើម គឺជាកន្លែងដ៏ល្អសម្រាប់បម្រុងរាងកាយ និងធ្វើការហ្វឹកហ្វឺនជាមូលដ្ឋាន។ រាល់រដូវរងាដល់និទាឃរដូវ មានក្រុមកីឡាក្នុងនិងក្រៅស្រុកជាច្រើនមកហ្វឹកហ្វឺននៅមូលដ្ឋានហ្វឹកហ្វឺនកីឡានានានៅទីក្រុងគុនមីញ ដូចជា មូលដ្ឋានហ្វឹកហ្វឺនកីឡាហៃកឿង មូលដ្ឋានហ្វឹកហ្វឺនកីឡានៅឃុំសុងម៉ាវ ស្រុកឆឹងកុង មូលដ្ឋានហ្វឹកហ្វឺនបឹយចោឆាង សម្រាប់កីឡាបាញ់ និងមូលដ្ឋានហ្វឹកហ្វឺនកីឡាហុងថាជាដើម។ កីឡាករខ្លះបានទទួលផលល្អក្នុងការប្រកួតកីឡា ឧទាហរណ៍កីឡាការិនី Yakusuimu ដែលជាកីឡាការិនីជប៉ុនធ្លាប់បានមកហ្វឹកហ្វឺននៅទីក្រុងគុនមីញអស់រយៈពេលមួយខែនៅពេលមុននឹងសន្និសីទកីឡាអូឡាំពិកទីក្រុងអាតែន ឆ្នាំ ២០០៤ ហើយបានទទួលជើងឯកក្នុងការប្រកួតកីឡារត់ម៉ារ៉ាតុង។



តាមព័ត៌មានថា ក្នុងមួយឆ្នាំៗ ទីក្រុងគុនមីញមាន ៣០០ថ្ងៃជាង គឺធ្វើការហ្វឹកហ្វឺននៅឯក្រៅ គឺមានលក្ខខណ្ឌធម្មជាតិដ៏កម្រមាននៅទូទាំងសកលលោក។ រាល់ឆ្នាំ គ្រាន់តែមូលដ្ឋានហ្វឹកហ្វឺនកីឡាហៃកឿង និងមូលដ្ឋានហ្វឹកហ្វឺនកីឡានៅឃុំសុងម៉ាវ ស្រុកឆឹងកុង បានទទួលកីឡាករក្នុង និងក្រៅស្រុកដល់ចំនួន១៥ម៉ឺននាក់ ៕

## ការប្រកួតរថយន្ត Auto Cross អន្តរជាតិនៅស្រុកដុងឈាន់នឹងត្រូវប្រារព្ធឡើងនៅថ្ងៃទី១ ខែឧសភា









បច្ចុប្បន្ននេះ សន្និសីទកាសែតនៃការប្រកួត Auto Cross អន្តរជាតិ និងជាការប្រកួតជើងឯក Auto Cross ប្រទេសចិន ឆ្នាំ២០១៥ បានធ្វើឡើងនៅទីក្រុងគុនមីញ ហើយបានប្រកាសថា ការប្រកួតឆ្នាំនេះនឹងត្រូវប្រារព្ធឡើងនៅថ្ងៃទី១ដល់៦ ខែឧសភា។

ស្រុកដុងឈាន់ ស្ថិតនៅភាគខាងកើតនៃទីក្រុងគុនមីញ។ កន្លែងសម្រាប់ប្រកួតនៃឆ្នាំនេះសំខាន់មានផ្លូវថ្មក្រួស ផ្លូវមានទឹក និងផ្លូវមានដីភក់ជាដើម ការប្រកួតនឹងចែកជាកំណាត់ប្រកួតចំនួន ៩ ក្នុងនោះចម្ងាយនៃកំណាត់ពិបាកពិសេសមាន៣៥៥គីឡូម៉ែត្រ។ ការប្រកួតឆ្នាំនេះនឹងចែកជាក្រុម T1-1/T1-2 សម្រាប់រថយន្តកែប្រែក្រុម T3 សម្រាប់រថយន្តហ្សីបក្រុមចំហសម្រាប់រថយន្ត UTV និង BUGGY និងក្រុម T4 សម្រាប់ឡានដឹកទំនិញធំៗ។ លក្ខណៈពិសេសធំបំផុតនៃការប្រកួតលើកនេះ គឺពិធីចេញដំណើរជាមួយគ្នានៃក្រុមចំហ គឺថារថយន្តទាំងអស់នឹងចេញដំណើរជាមួយគ្នាដែលខុសពីការប្រកួតពីមុនដែលមានតែឡាន ២គ្រឿងប្រកួតជាមួយគ្នា។ ទន្ទឹមនឹងការប្រកួតរបស់កីឡាករជំនាញ គណៈកម្មាធិកានៃការប្រកួតលើកនេះនូវបានចាត់ចែងការប្រកួតពិសេសមួយ គឺអនុញ្ញាតអ្នកបើកបរធម្មតាចូលរួមការប្រកួតដោយឡែកមួយ ដោយបើកបររថយន្តហ្សីបធម្មតារបស់ខ្លួន ដើម្បីបំពេញបំណងចូលរួមរបស់អ្នកចូលចិត្តប្រកួតរថយន្តធម្មតាយ៉ាងច្រើន។

តាមព័ត៌មានថា ការប្រកួតរថយន្ត Auto Cross អន្តរជាតិនៅស្រុកដុងឈាន់ ការប្រកួតរថយន្ត Auto Cross ព័ទ្ធវាលខ្សាច់ Taklimakan និងការប្រកួតរថយន្ត Auto Cross ប្រទេសចិនគឺជាការប្រកួតរថយន្ត Auto Cross ធំបំផុតទាំងបីនៃប្រទេសចិន។ ឥឡូវនេះមានរថយន្តច្រើនជាងមួយរយគ្រឿងបានចុះឈ្មោះក្នុងការប្រកួតលើកនេះ។ គេរំពឹងថានឹងមានរថយន្តច្រើនជាង ១៦០ គ្រឿងនឹងចូលរួមការប្រកួតលើកនេះ៕

**ចាំង តឹង**





